**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ........................................................

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ពិធីប្រកាសផ្សព្វផ្សាយ
# លទ្ធផលអង្កេតវិនិយោគផ្ទាល់បរទេស ឆ្នាំ២០១៤

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៦ ធនាគារជាតិនៃកម្ពុជា សហការជាមួយវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ បានរៀបចំពិធីប្រកាសផ្សព្វផ្សាយ **លទ្ធផលអង្កេតវិនិយោគផ្ទាល់បរទេស ឆ្នាំ២០១៤** នៅសណ្ឋាគារកាំបូឌីយ៉ាណា ។ ធនាគារជាតិនៃកម្ពុជា បានចុះហត្ថលេខាជាផ្លូវការជាមួយវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ លើកិច្ចព្រមព្រៀង ស្តីពី **ការអង្កេតវិនិយោគផ្ទាល់បរទេស ឆ្នាំ២០១៤** កាលពីថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៥ ។ ការចុះអង្កេតតាមក្រុមហ៊ុន រោងចក្រ សហគ្រាស បានចាប់ផ្តើមធ្វើឡើងក្នុងអំឡុងពេលពីខែកញ្ញា ឆ្នាំ២០១៥ រហូតដល់ ខែមករា ឆ្នាំ២០១៦ ។ ការអង្កេតនេះ មានសំណាកគំរូ ១២៤ ក្រុមហ៊ុន រោងចក្រ សហគ្រាស គ្របដណ្តប់លើវិស័យវិនិយោគផ្ទាល់បរទេសនៅកម្ពុជា ។

ពិធីប្រកាសផ្សព្វផ្សាយនេះ ត្រូវបានប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ លោកជំទាវ **នាង ច័ន្ទថាណា** ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា ព្រមទាំងមានការចូលរួមពីតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល វិស័យឯកជន មន្ត្រីធនាគារជាតិនៃកម្ពុជា មន្ត្រីវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ ព្រមទាំងស្ថាប័នអន្តរជាតិ ដៃគូអភិវឌ្ឍន៍ សភាពាណិជ្ជកម្ម អ្នកស្រាវជ្រាវ ផងដែរ ។

លទ្ធផលអង្កេតវិនិយោគផ្ទាល់បរទេសមានសារៈសំខាន់ណាស់ ចំពោះធនាគារជាតិនៃកម្ពុជា ក៏ដូចជាប្រទេសកម្ពុជាទាំងមូល ផងដែរ ។ លទ្ធផលនេះ ត្រូវបានប្រើប្រាស់សម្រាប់ចងក្រងស្ថិតិជញ្ជីងទូទាត់ និងស្ថានភាពវិនិយោគអន្តរជាតិរបស់កម្ពុជា និងជាធាតុចូលដ៏សំខាន់មួយក្នុងការកំណត់នូវគោលនយោបាយសេដ្ឋកិច្ច ការរៀបចំផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រ និងការសិក្សាស្រាវជ្រាវពាក់ព័ន្ធនឹងបញ្ហាសាកលភាវូបនីយកម្ម ។ លើសពីនេះ ការធ្វើអង្កេតនេះបានផ្តល់នូវឱកាសដ៏ល្អដល់មន្ត្រីជំនាញរបស់ធនាគារជាតិនៃកម្ពុជា និងមន្ត្រីជំនាញរបស់វិទ្យាស្ថានជាតិស្ថិតិ ដើម្បីកសាងសមត្ថភាពធនធានមនុស្ស និងផ្តល់នូវកិច្ចសហប្រតិបត្តិការការយ៉ាងជិតស្និទ្ធ និងផ្លាស់ប្តូរបទពិសោធន៍ជាក់ស្តែង និងចែករំលែកចំណេះដឹងគ្នាវិញទៅមក ។

មានបទបង្ហាញចំនួនពីរដែលត្រូវបានធ្វើឡើងក្នុងពិធីប្រកាសផ្សព្វផ្សាយនេះ (១) បទបង្ហាញស្តីពី **ដំណើរការ និងវិធីសាស្ត្រអង្កេត** ដោយផ្តោតសំខាន់ទៅលើ វិធីសាស្ត្រការជ្រើសរើស និងកំណត់សំណាក

គំរូអង្កេត ការរៀបចំលិខិតរដ្ឋបាលផ្សេងៗពាក់ព័ន្ធនឹងការអង្កេត និងអំពីបញ្ហាប្រឈមក្នុងការធ្វើអង្កេតនេះ ដោយតំណាងពីវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ និង (២) បទបង្ហាញស្តីអំពី **របកគំហើញនៃការធ្វើអង្កេតវិនិយោគផ្ទាល់បរទេស ឆ្នាំ២០១៤** ដោយផ្តោតជាពិសេសទៅលើលទ្ធផលដែលទទួលបានពីការអង្កេត និងការធ្វើការប៉ាន់ស្មានបំពេញបន្ថែម ដើម្បីធ្វើការកែតម្រូវបកក្រោយនូវទិន្នន័យវិនិយោគផ្ទាល់បរទេសដែលបានចេញផ្សាយកន្លងមករហូតដល់ឆ្នាំ២០១០ ដោយតំណាងពីធនាគារជាតិនៃកម្ពុជា ។